ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម
AGRICULTURAL AND RURAL DEVELOPMENT BANK
ដើម្បីកសិករនិងអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គម

# គម្រោងអាជីវកម្ម
# ចិញ្ចឹមមាន់បីសាសន៍



រៀបចំដោយ

**នាយកដ្ឋានគាំទ្រគោលនយោបាយរបស់រាជរដ្ឋាភិបាលនៃ**
**ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម**

ខែកុម្ភៈ ឆ្នាំ២០២៦

023 220 811
023 220 810
095 416 878
# 168, Street 7, Prek Leap Village, Sangkat Prek Leap, Khan Chroy Changva, Phnom Penh

# មាតិកា

**១- សេចក្តីផ្តើម** ........ ១
**២-លក្ខណៈទូទៅ**........ ១
**៣-បច្ចេកទេសចិញ្ចឹម** ........ ២
៣-១-ការជ្រើសរើសកូនមាន់មកចិញ្ចឹម........ ២
៣-២-ការសាងសង់រោង និងបរិវេណជុំវិញរោងមាន់ ........ ២
៣-៣-ស្នូកទឹក និងការផ្តល់ទឹក........ ៤
៣-៤-ស្នូកចំណី និងការផ្តល់ចំណីអាហារ........ ៤
៣-៥-ការថែទាំ........ ៥
៣-៦-ការគ្រប់គ្រង និងការធ្វើអនាម័យ ........ ៦
៣-៧-កម្មវិធីវ៉ាក់សាំងមាន់សាច់បីសាសន៍........ ៨
**៤-ការវិភាគសេដ្ឋកិច្ច**........ ៨
៤-១-ចំណាយលើការចាប់ផ្តើមអាជីវកម្មដំបូង........ ៩
៤-២-គម្រោងចំណាយ-ចំណូលលម្អិត និងលទ្ធផល ........ ៩
៤-៣-លទ្ធភាពចំណេញក្នុង១វគ្គ ដោយផ្អែកលើទិន្នាការតម្លៃ........ ១០
**៥-හានិភ័យ វិធានការ និងអនុសាសន៍**........ ១១
**៦-សេចក្តីសន្និដ្ឋាន**........ ១២

## ១- សេចក្តីផ្តើម

ការចិញ្ចឹមមាន់សាច់បីសាសន៍គឺជាមុខរបរកសិកម្មដែលមានសក្តានុពលខ្ពស់នៅកម្ពុជា ដោយសារមាន់ប្រភេទនេះឆាប់ធំធាត់ មាឌធំ ធន់នឹងជំងឺ និងអាកាសធាតុ ព្រមទាំងមានសាច់ឆ្ងាញ់ដូចមាន់ស្រុក។ វាជាជម្រើសល្អសម្រាប់កសិករចិញ្ចឹមជាលក្ខណៈគ្រួសារ ឬពាណិជ្ជកម្ម ដើម្បីបង្កើនប្រាក់ចំណូលដែលអាចទទួលបានប្រាក់ចំណេញសមល្មមទៅតាមរដូវកាល។

មុនចាប់ផ្តើមប្រកបរបរចិញ្ចឹមមាន់សាច់បីសាសន៍ ទោះបីការចិញ្ចឹមជាលក្ខណៈគ្រួសារក្តី កសិករគួរយល់ដឹងឱ្យបានច្បាស់នូវបច្ចេកទេសចិញ្ចឹម ជាពិសេសបច្ចេកទេសថ្មីៗដែលធន់នឹងបម្រែបម្រួលអាកាសធាតុ ដូចជា ការផ្តល់កម្តៅ ការជ្រើសរើសពូជ ការសាងសង់ទ្រុង ការផ្តល់ចំណី ការថែទាំ និងការការពារជាដើម ទើបអាចទទួលបានផលល្អ និងអាចជួយកាត់បន្ថយលើការចំណាយថ្លៃដើមចិញ្ចឹម។ មួយវិញទៀត ដើម្បីឱ្យការចិញ្ចឹមមាន់ទទួលបានទិន្នផលល្អ ប្រកបដោយគុណភាពខ្ពស់ ត្រូវចាប់ផ្តើមពីកូនមាន់ដែលមានសុខភាពល្អ ចិញ្ចឹមហើយកូនមាន់ឆាប់ធំ ផ្តល់សាច់ច្រើន។

## ២-លក្ខណៈទូទៅ

មាន់សាច់បីសាសន៍ដែលកសិករនិយមចិញ្ចឹមមានលក្ខណៈសម្បត្តិដូចជា÷ លូតលាស់លឿន បម្លែងចំណីទៅជាសាច់បានល្អ (Feed Conversion Ratio ល្អ) សាច់ស្វិតរឹង រសជាតិឆ្ងាញ់សាកសមនឹងចំណង់ចំណូលចិត្តប្រជាជន និងទីផ្សារកម្ពុជា។ ពូជមាន់នេះអាចសម្របខ្លួនបានល្អនឹងអាកាសធាតុ សំណើម អត្រាស្លាប់ទាប ប្រសិនបើគ្រប់គ្រងបានត្រឹមត្រូវ រយៈពេលចិញ្ចឹមជាមធ្យម ៨-១០សប្តាហ៍ ទម្ងន់លក់ ១.២-១.៤ គក្រ/ក្បាល ។



## ៣- បច្ចេកទេសចិញ្ចឹម

### ៣-១-ការជ្រើសរើសកូនមាន់មកចិញ្ចឹម

ជ្រើសរើសកូនមាន់អាយុ ១ថ្ងៃមកចិញ្ចឹម ដែលមានទម្ងន់ស្តង់ដារ ៣៨ ទៅ ៥០ក្រាម កែវភ្នែកភ្លឺថ្លា មិនស្រអាប់ ពោះមានសភាពទន់ ជើងមូលរលោង ជើងរឹងមាំ មិនវៀច ឬខូចទ្រង់ទ្រាយ រោមទន់ភ្លឺរលោង មានសកម្មភាពរហ័ស ការចិញ្ចឹមកូនមាន់អាយុ ១ថ្ងៃ មានគុណសម្បត្តិដូចខាងក្រោម÷

**គុណសម្បត្តិ÷**

- កូនមាន់អាយុ ១ថ្ងៃអាចចិញ្ចឹមរាងកាយដោយខ្លួនឯងបាន ដោយប្រើនូវសារធាតុចិញ្ចឹមក្នុងខ្លួនពណ៌លឿងរបស់វា ដូច្នេះក្នុងរយៈពេល១ ឬ២ថ្ងៃ កូនមាន់មិនត្រូវការចំណី ឬទឹកក្នុងអំឡុងពេលដឹកជញ្ជូនយកទៅកន្លែងថ្មីទេ
- មានសមត្ថភាពបម្លែងចំណីទៅជាសាច់បានល្អ (FCR) ២.០ ទៅ ២.៤
- ធន់នឹងអាកាសធាតុក្នុងតំបន់បានល្អ
- ទិញចូលកូនមាន់អាយុ១ថ្ងៃ ងាយស្រួលរៀបចំកម្មវិធីវ៉ាក់សាំង ប្រកបដោយទំនុកចិត្ត។

***លក្ខណៈសម្បត្តិរបស់កូនមាន់ដែលត្រូវជ្រើសរើសយកមកចិញ្ចឹម÷***

- មានអាយុដំណាលៗគ្នា ញាស់ក្នុងថ្ងៃតែមួយ
- មានទំហំ ទម្ងន់ និងពណ៌សម្បុរដូចគ្នាៗ
- មានរោមទន់ភ្លឺរលោង ជើងមូលរលោង មិនស្វិត
- មានកែវភ្នែកភ្លឺថ្លា សំឡេងច្បាស់ រហ័សរហួន ពុំមានលាមកស្អិតជាប់គូទ

### ៣-២-ការសាងសង់រោង និងបរិវេណជុំវិញរោងមាន់

រោងមាន់ត្រូវមានលក្ខណៈសមស្របមួយចំនួនដូចតទៅ÷

- រោងត្រូវសង់បែរមុខចេញពីទិសរបស់ខ្យល់ ប៉ុន្តែត្រូវធ្វើយ៉ាងណាឱ្យខ្យល់អាចចេញចូលបានល្អ
- ដីខ្ពស់ មិនលិចទឹក និងមានអគ្គិសនីគ្រប់គ្រាន់
- កម្រាលត្រូវធ្វើឱ្យទឹកអាចហូរចេញបាន ដើម្បីការពារកុំឱ្យសើម
- ឆ្ងាយពីផ្ទះរស់នៅ ២០ ទៅ ៣០ម៉ែត្រ និងឆ្ងាយពីភូមិផ្ទះប្រជាពលរដ្ឋផ្សេងៗ ៥០០ម៉ែត្រ

**ក-ការធ្វើឱ្យខ្យល់ចេញចូល**

រោងចិញ្ចឹមមាន់បែបពាណិជ្ជកម្មត្រូវសាងសង់រោងឱ្យខ្យល់ចេញចូលល្អ ឬដាក់កង្ហារ។

### ខ-បរិវេណជុំវិញរោងចិញ្ចឹម

តម្រូវការទីធ្លាបរិវេណជុំវិញរោង ដើម្បីជាចន្លោះសុវត្ថិភាពការពារពីភ្នាក់ងារចម្លងជំងឺដោយផ្ទាល់តាមរយៈឆ្មា ឆ្កែ កណ្ដុរ បក្សីស្រុក បក្សីព្រៃ ឬសត្វល្អិតផ្សេងៗ ដឹកនាំមេរោគមកពីប្រភពខាងក្រៅ។ ត្រូវសម្អាតស្មៅ និងរុក្ខជាតិផ្សេងៗឱ្យស្អាត ដើម្បីលុបបំបាត់កន្លែងសំងំប្រភពមេរោគ និងដើម្បីមានខ្យល់អាចចេញចូលគ្រប់គ្រាន់។

### គ-ការធ្វើទ្រុង

ត្រូវធ្វើរោងមាន់ដែលមានកម្ពស់ចន្លោះពី ២,៥ ទៅ ៣ម៉ែត្រ ចំណែកបណ្ដោយ និងទទឹង អាចសាងសងអាស្រ័យចំនួនមាន់ ហើយត្រូវសង់ទៅតាមគំរូប្លង់រោងចិញ្ចឹមមាន់។



### ឃ-ដំបូល

ដំបូលសម្រាប់ការពារទឹកភ្លៀង អាចប្រើប្រាស់ស៊ីប្រូ ស្បូវ ស័ង្កសី ។ល។ នៅរដូវក្ដៅត្រូវធ្វើសំយ៉ាបរោង ដើម្បីការពារការជះកម្ដៅខ្លាំងពេក និងធ្វើយ៉ាងណាឱ្យមានពន្លឺថ្ងៃចូលគ្រប់គ្រាន់នៅរដូវរងារ។



**ង-កម្រាល**

ប្រភេទនៃកម្រាលប្រែប្រួលទៅតាមសណ្ឋានផ្សេងៗគ្នារួមមានកម្រាលផ្ទាល់ដីកម្ពស់ ៨ ទៅ១០ស.ម ស្ងួត ស្អាត មិនមានផ្សិត និងត្រូវប្តូរ ឬបន្ថែមអង្កាមឱ្យបានញឹកញាប់។

## ៣-៣-ស្នូកទឹក និងការផ្តល់ទឹក

-ត្រូវសម្អាតស្នូកទឹក និងមានទឹកត្រជាក់សម្រាប់មាន់ផឹកគ្រប់គ្រាន់ ជាទូទៅមាន់ត្រូវការផឹកទឹករៀងរាល់១៥-២០នាទីម្តង។ទឹកដែលផ្តល់ត្រូវមានអនាម័យ ស្នូកទឹកតម្រូវទៅតាមអាយុ និងកម្ពស់របស់មាន់។

-ទឹកមាននាទីសំខាន់ណាស់នៅក្នុងចំណីអាហាររបស់មាន់វាធ្វើឱ្យចំណីទន់ ដែលចូលរួមប្រតិកម្មអ៊ីដ្រូលីសសម្រាប់ការរំលាយអាហារ ដឹកជញ្ជូនសារជាតិពុលចេញទៅក្រៅសារពាង្គកាយ ជួយរក្សាសីតុណ្ហភាពក្នុងខ្លួន មាន់មិនអាចស៊ីចំណីតាមសេចក្តីត្រូវការបានទេ នៅពេលណាដែលវាពុំមានទឹកគ្រប់គ្រាន់ ជាហេតុធ្វើឱ្យមាន់លូតលាស់យឺត ផលិតកម្មថយចុះ ហើយងាយនឹងទទួលជំងឺ ។

*តម្រូវការទឹកប្រចាំថ្ងៃសម្រាប់មាន់*

| អាយុមាន់(សប្តាហ៍) | ០-២ | ២-៥ | ៥-១០ | ១០-២០ |
|---|---|---|---|---|
| បរិមាណ(លីត្រ/ថ្ងៃ) | ៥-៤ | ៧-១០ | ១៥ | ១៨ |



## ៣-៤- ស្នូកចំណី និងការផ្តល់ចំណីអាហារ

-ស្នូកចំណីមាន់អាចប្រើប្រាស់ស្នូកចំណីដែលទិញពីទីផ្សារ។ កសិករត្រូវដាក់ស្នូកចំណីរាយជាជួរឱ្យបានច្រើនគ្រប់គ្រាន់ ដើម្បីឱ្យមាន់ស៊ីចំណីបានក្នុងពេលជាមួយគ្នា មិនដូច្នេះទេមាន់អាចក្រិន ធំធាត់មិនស្មើគ្នា។ គម្លាតចន្លោះដែលគួរតម្រាប់ស្នូកសម្រាប់មាន់ត្រូវមានដង់ស៊ីតេ ៣០ ទៅ៤០ក្បាល/ស្នូក។

-តម្រូវការចំណីអាហារ ដើម្បីទទួលបានថាមពល និងសារធាតុចិញ្ចឹមសម្រាប់ការលូតលាស់ សារធាតុចិញ្ចឹមបានដែលផ្តល់ឱ្យបក្សីនូវថាមពល និងសមាសធាតុដែលវាត្រូវការសម្រាប់ការលូតលាស់ឆ្អឹង សាច់ ឈាម រោម និងស៊ុត។ តម្រូវការទាំងនោះមានរួមមាន ប្រូតេអ៊ីន ថាមពល សារធាតុខនិជ វីតាមីន និងទឹក ។

*តម្រូវការសារធាតុចិញ្ចឹមសម្រាប់មាន់សាច់បីសាសន៍*

| សារធាតុ | អាយុ០-៣សប្តាហ៍ | អាយុ៣-៦សប្តាហ៍ | អាយុ៦-៨សប្តាហ៍ |
|---|---|---|---|
| ប្រូតេអ៊ីន % | ២១ | ២០ | ១៨ |
| ថាមពល (Kcal/kg) | ៣២០០ | ៣២០០ | ៣២០០ |
| កាល់ស្យូម % | ១ | ០,៩ | ០,៨ |
| ផូស្វ័រ % | ០,៤៥ | ០,៣៥ | ០,៣៥ |

### ៣-៥-ការថែទាំ

**ក-កម្តៅ**

កូនមាន់ត្រូវការកម្តៅ ខ្យល់បរិសុទ្ធ កម្រាលស្ងួត ចំណីអាហារ និងទឹកដែលមានគុណភាពល្អ។

| អាយុមាន់ | សីតុណ្ហភាព |
|---|---|
| ០-១ សប្តាហ៍ | ៣៥ ℃ |
| ១-២ សប្តាហ៍ | ៣០ ℃ |
| ២-៣ សប្តាហ៍ | ២៦ ℃ |
| ៣-៤ សប្តាហ៍ | ២៣ ℃ |
| ៤សប្តាហ៍ ដល់លក់ | ២៣ ℃ |

**ខ- ពន្លឺ**

ផ្តល់ពន្លឺពី ១៨ ទៅ ២២ ម៉ោងសម្រាប់សប្តាហ៍ដំបូង។ បន្ទាប់មកកាត់បន្ថយពន្លឺមកត្រឹមតែ ១៦ ម៉ោងតាមរយៈពេលលូតលាស់ គន្លឹះមួយក្នុងការកាត់បន្ថយការខាតបង់ផលិតកម្មក្នុងកំឡុងអាកាសធាតុក្តៅ គឺការរៀបចំប្រព័ន្ធខ្យល់ឱ្យបានត្រឹមត្រូវ។

### គ- សំណើម

តម្រូវការសំណើមរបស់មាន់

| អាយុមាន់(សប្ដាហ៍) | ០ | ១ | ២ | ៣ | ៤ | ៥ |
|---|---|---|---|---|---|---|
| សំណើម(%) | ៣០-៥៤ | ៤០-៦០ | ៤០-៦០ | ៤០-៦០ | ៥០-៧០ | ៥០-៧០ |

### ឃ- ខ្យល់

ខ្យល់មានតួនាទីជាអ្នកដឹកនាំកម្ដៅចេញពីក្នុងខ្លួនមាន់ ដែលលើសពីសេចក្ដីត្រូវការ ប៉ុន្តែវាក៏ជាមូលហេតុធ្វើឱ្យបក្សីបាត់បង់កម្ដៅពីក្នុងខ្លួនផងដែរ។ កាលណាខ្យល់បក់មិនគ្រប់គ្រាន់ វិខ្វះខាតបណ្ដាលឱ្យខ្វះអុកស៊ីសែន ព្រោះអុកស៊ីសែនសំបូរច្រើននៅក្នុងខ្យល់ ហើយបណ្ដាលឱ្យកើនឡើងនូវបរិមាណអាម៉ូញាក់ និងឧស្ម័នកាបូនិច ដែលបង្កជាផលប៉ះពាល់ដល់ការរំលាយអាហារ និងធ្វើឱ្យមាន់លូតលាស់យឺត បង្កើនការប្រឈមមុខនឹងជំងឺផ្សេងៗ ។

## ៣-៦-ការគ្រប់គ្រង និងការធ្វើអនាម័យ

### ក- ការគ្រប់គ្រងឧបករណ៍ប្រើប្រាស់ក្នុងរោង

ការធ្វើអនាម័យគឺជាកត្តាសំខាន់មួយ ដែលនាំឱ្យការចិញ្ចឹមមាន់ទទួលបានជោគជ័យ គួរតែធ្វើឡើងឱ្យបាន៣សប្ដាហ៍មុនការដាក់កូនមាន់ចិញ្ចឹម តាមរយៈការបោសសម្អាតបរិវេណចិញ្ចឹមទាំងខាងក្នុង និងខាងក្រៅ។ បន្ទាប់មកចាប់ផ្ដើមបាចកំបោរសម្លាប់ទុកចោលរយៈពេល ១សប្ដាហ៍ រួចហើយទើបធ្វើការលាងសម្អាតចេញឱ្យបានស្អាត និងបាញ់ថ្នាំសម្លាប់មេរោគជុំវិញបរិវេណរោងចិញ្ចឹមឱ្យបាន ៤ថ្ងៃមុនពេលដាក់កូនមាន់ចិញ្ចឹម។ ចំពោះស្នូកទឹក និងស្នូកចំណី ត្រូវធ្វើការលាងសម្អាតឱ្យបានស្អាតយ៉ាងហោចណាស់ឱ្យបាន ២ដងក្នុងមួយថ្ងៃ។ អង្កាមដែលត្រូវយកមកធ្វើជាកម្រាល ត្រូវក្រាលក្រោមពន្លឺ អំពូលអគ្គិសនីរយៈពេល២៤ម៉ោងមុនពេលយកកូនមាន់មកដាក់។ ការធ្វើដូច្នេះគឺដើម្បីឱ្យសីតុណ្ហភាពក្នុងរោងមានលក្ខណៈ សមស្របល្អជាមួយនឹងមជ្ឈដ្ឋានរស់នៅរបស់កូនមាន់។




### ខ- ការរំងាប់មេរោគ

ការចិញ្ចឹមមាន់ឱ្យបានធំធាត់ និងជៀសវាងពីជំងឺផ្សេងៗដែលអាចប៉ះពាល់ដល់ការចិញ្ចឹមដោយពពួកមេរោគ ឬវីរុស។ ដូច្នេះត្រូវធ្វើការសម្លាប់មេរោគមុនពេលយកកូនមាន់មកដាក់ចិញ្ចឹម។

វិធានការណ៍មានដូចតទៅ÷

- បោសសម្អាតខាងក្នុង និងខាងក្រៅរោងដែលជាបរិវេណសម្រាប់ចិញ្ចឹម។
- កាប់ឆ្ការព្រៃដែលដុះនៅជុំវិញកន្លែងចិញ្ចឹមឱ្យបានស្អាត ដើម្បីឱ្យមានចរន្តខ្យល់ចេញចូលបានល្អ។
- នៅខាងមុខរោងមាន់ត្រង់ច្រកចេញចូល ត្រូវមានអាងតូចមួយដោយដាក់កំបោរ ឬថ្នាំសម្លាប់មេរោគលាយ ទឹកសម្រាប់ជ្រលក់ជើងមុនពេលចូលរោង។
- បាចកំបោរនៅក្នុងរោងចិញ្ចឹម និងនៅបរិវេណជុំវិញរោងមាន់រួចទុកចោលរយៈពេលមួយសប្តាហ៍ បន្ទាប់មកត្រូវលាងឱ្យស្អាត។ ក្រាលអង្កាមបន្ទាប់មកបាញ់ថ្នាំសម្លាប់មេរោគទៅលើអង្កាមរួចទុកចោលរយៈពេលមួយសប្តាហ៍ មុនដាក់កូនមាន់។

**គ- ការរៀបចំរោងមុនពេលដាក់កូនមាន់**

មុនពេលយកកូនមាន់មកដល់ យើងត្រូវត្រៀមរៀបចំកន្លែងឱ្យរួចជាស្រេចសម្រាប់ដាក់កូនមាន់ សម្ភារដែលត្រូវប្រើដូចជា÷

- ប្រអប់ក្រដាស ឬបាវសម្រាប់ទប់ស្កាត់កម្តៅ
- រៀបចំចំណីទុកជាមុន មុនពេលដាក់កូនមាន់
- រៀបចំស្នូកទឹក និងស្នូកចំណី
- វ៉ាក់សាំង
- វីតាមីន និងអង់ទីប៊ីយ៉ូទិករៀបចំទុកដាក់ជាមុន
- អំពូលកម្តៅ ១០០ វ៉ាត់
- ធុងបាញ់ថ្នាំសម្លាប់មេរោគ

**ឃ- ការធ្វើប្រព័ន្ធជីវៈសុវត្ថិភាព និងការការពារ**

ការការពារគឺជាគន្លឹះសំខាន់នៃការទប់ស្កាត់ជំងឺទាំងឡាយរបស់មាន់ ជាទូទៅការការពារអាចសម្រេចបានយ៉ាងល្អប្រសើរដោយគោលការណ៍អនាម័យដែលត្រូវអនុវត្តមាន÷

-ហាមភ្ញៀវ (រួមទាំងអ្នកជិតខាង) បក្សីព្រៃ សត្វកកេរ ចូលទៅក្នុងរោងចិញ្ចឹមមាន់

-បន្ទាប់ពីការចូលមើលរោងមាន់អ្នកផ្សេង ត្រូវសម្អាតខ្លួនប្រាណ ផ្លាស់ប្តូរសម្លៀកបំពាក់ និងស្បែកជើងមុនចូលទៅក្នុងរោងមាន់

-ត្រូវយកក្រដាសឡាំងកខ្វក់ បាវចំណី និងវត្ថុណាដែលកខ្វក់ផ្សេងៗទៀតចេញពីរោងមាន់

-បង្កើតបែបបទ“ចូលទាំងអស់ ចេញទាំងអស់”ដើម្បីធ្វើឱ្យមានកន្លែងដាក់មាន់ទៅតាមអាយុដូចគ្នា។

-បើមានមាន់ងាប់ត្រូវនាំយកចេញពីក្នុងរោងជាប្រញាប់ ដោយយកទៅដុតចោល ឬកប់ឱ្យជ្រៅ។

### ៣-៧-កម្មវិធីវ៉ាក់សាំងមាន់សាច់បីសាសន៍

| អាយុមាន់ | ប្រភេទវ៉ាក់សាំង | ការការពារលើជំងឺ | ការប្រើប្រាស់ | កម្រិតប្រើ |
|---|---|---|---|---|
| ៣-៥ថ្ងៃ | ញ៉ូវកាស | ញ៉ូវកាស | បន្តក់ភ្នែកច្រមុះ ឬមាត់ | ១ដំណក់ |
| ១៤ថ្ងៃ | ហ្គូមបូរ៉ូ | ហ្គូមបូរ៉ូ | បន្តក់ភ្នែកឬលាយទឹក | ១ដំណក់ |
| ២១ថ្ងៃ | H5N1+H9N2 | ផ្តាសាយបក្សី | ចាក់សើរស្បែក | ០.៣ម.ល |
| ២៥ថ្ងៃ | ញ៉ូវកាស | ញ៉ូវកាស | បន្តក់ភ្នែកច្រមុះ ឬមាត់ | ១ដំណក់ |
| ៤៥ថ្ងៃ | អាសន្នរោគ | អាសន្នរោគ | ចាក់សាច់ដុំទ្រូង | ០,២៥ សេសេ |

## ៤-ការវិភាគសេដ្ឋកិច្ចលើការចិញ្ចឹមមាន់សាច់បីសាសន៍

**កសិករ** ÷ ភូមិដូង ឃុំភ្នំតូច ស្រុកសាមគ្គីមុនីជ័យ ខេត្តកំពង់ស្ពឺ

**ទំហំផ្ទៃដីចិញ្ចឹម** ÷ ៥០ អា (៥,០០០ម៉ែត្រការ៉េ)

**ចំនួនមាន់ចិញ្ចឹម** ÷ ១២,០០០ ក្បាល

**របៀបចិញ្ចឹម** ÷ ចិញ្ចឹមក្នុងរោងមាន់ ផ្តល់វ៉ាក់សាំង ថ្នាំ វីតាមីន ទឹក និងចំណីសម្រេចក្រុមហ៊ុន

**ចំនួនរោង** ÷ រោងចំនួន១ (ទំហំ ១២ម៉ x៩០ម៉) ប្រក់ស័ង្កសី ដំបូល២ជាន់

**ប្រភេទមាន់** ÷ ជាមាន់សាច់បីសាសន៍ មានស្បែកលឿង ជើងលឿងលាយខ្មៅ រោមពណ៌ត្រសក់ក្រហម និងខ្មៅ

**ទិន្នផល** ÷ មាន់អាយុ ៦០ថ្ងៃ, ទម្ងន់មាន់ដែលទទួលបានជាមធ្យម ១,៣គក្រ/ក្បាល

**រយៈពេលចិញ្ចឹម** ÷ ចិញ្ចឹមរយៈពេលចំនួន ៦០ថ្ងៃ(២ខែ) និងសម្អាតរោង សម្លាប់មេរោគចំនួន ៣០ថ្ងៃ (១ខែ)ក្នុង១ឆ្នាំអាចចិញ្ចឹមបាន ៤វគ្គ

**តម្លៃ** ÷ តម្លៃក្នុងតំបន់ចន្លោះពី ៧,០០០៛ ទៅ ១០,០០០៛/គក្រ និងអាចឡើងដល់ ១១,០០០៛/គក្រ នៅរដូវកាលចូលឆ្នាំចិន ឬបុណ្យទាន (តម្លៃគិតជាមធ្យម ៨ ៥០០៛ ក្នុង១គីឡូក្រាម)

**ទីផ្សារ** ÷កសិករលក់មាន់សាច់(រស់)ឱ្យឈ្មួញយកទៅចែកចាយបន្តនៅភ្នំពេញ ឬទីប្រជុំជនរោងចក្រនានា។

**អត្រាបាត់បង់** ÷ អត្រាមាន់បាត់បង់មានចំនួន ៤%នៃចំនួនមាន់សរុប (ស្លាប់ចំនួន ៤៨០ក្បាល និងរស់ ១១,៥២០ក្បាល x ១,៣គក្រ/ក្បាល = ១៤ ៩៧៦ គក្រ)

### ៤-១-ចំណាយលើការចាប់ផ្តើមអាជីវកម្មដំបូង÷

| ចំណាយវិនិយោគលើការរៀបចំរោងមាន់ អំពូល កម្តៅ និងសម្ភារៈផ្សេងៗ | ចំណាយលើការចិញ្ចឹម-ថែទាំ (ចំណី និងវ៉ាក់សាំង) | **ចំណាយសរុបពេលចាប់ផ្តើមអាជីវកម្ម** |
|---|---|---|
| **224,480,000** រៀល | **105,048,400** រៀល | **329,528,400** រៀល |

### ៤-២-គម្រោងចំណាយ-ចំណូលលម្អិត និងលទ្ធផល÷

| **បរិយាយ** | **ឯកត្តា** | **ចំនួនឯកត្តា** | **តម្លៃ ១ឯកត្តា** | **ទឹកប្រាក់សរុប (៛)** | **ចំនួនសាររំលស់** | **ទឹកប្រាក់សរុប (៛)** |
|---|---|---|---|---|---|---|
| **១-ចំណូលសរុប/(២ខែ)** | | | | | | **127,296,000** |
| ចំណូលពីការលក់មាន់ | គក្រ | 14,976 | 8,500 | 127,296,000 | | 127,296,000 |
| **២-ចំណាយសរុប = ចំណាយប្រែប្រួល + ចំណាយមិនប្រែប្រួល/ថេរ** | | | | | | **111,786,733** |
| **២.ក.ចំណាយប្រែប្រួល** | | | | | | **105,048,400** |
| កូនមាន់សាច់បីសាសន៍ | ក្បាល | 12,000 | 2,600 | 31,200,000 | | 31,200,000 |
| ចំណីសម្រេច ១ថ្ងៃ-២១ថ្ងៃ | បាវ | 549 | 54,600 | 29,975,400 | | 29,975,400 |
| ចំណីសម្រេច ២១ថ្ងៃ- លក់ | បាវ | 550 | 53,400 | 29,370,000 | | 29,370,000 |
| ថ្លៃអគ្គីសនី | គី.វ៉ាត់ | 1,100 | 730 | 803,000 | | 803,000 |
| ថ្នាំ និងវីតាមីន | គ.ក្រ | 30 | 40,000 | 1,200,000 | | 1,200,000 |
| កម្រាល (អង្កាម) | តោន | 5 | 100,000 | 500,000 | | 500,000 |
| វ៉ាក់សាំង | ក្បាល | 12,000 | 500 | 6,000,000 | | 6,000,000 |
| កម្លាំងពលកម្ម | នាក់ | 2 | 2,000,000 | 4,000,000 | | 4,000,000 |
| ថ្នាំសម្លាប់មេរោគ | ដប | 20 | 100,000 | 2,000,000 | | 2,000,000 |
| **២.ខ.ចំណាយមិនប្រែប្រួល/ថេរ (ក្នុង២ខែ)** | | | | **224,480,000** | | **6,738,333** |
| រោងមាន់ ទទឹង ១២ បណ្តោយ ៩០ រួមទាំងសម្ភារៈ | រោង | 200,000,000 | 1 | 200,000,000 | 40 | 5,000,000 |

| | | | | | | |
|---|---|---|---|---|---|---|
| សំណាក់ព័ន្ធជុំវិញបរិមាណរោង | គ.ក្រ | 50 | 30,000 | 1,500,000 | 30 | 50,000 |
| ប្រព័ន្ធស្នូកទឹក និងសីទែនស្តុកទឹក | ចំនួន | 5 | 4,000,000 | 20,000,000 | 20 | 1,000,000 |
| ស្នូកចំណី | ចំនួន | 500 | 5,000 | 2,500,000 | 12 | 208,333 |
| អំពូលកម្តៅ | ចំនួន | 120 | 4,000 | 480,000 | 1 | 480,000 |
| **៣-ចំណេញសរុប** | | | | | | **15,509,267** |
| **ថ្លៃដើមចំណាយលើមាន់សាច់បីសាសន៍ ១គ.ក្រ= ការចំណាយសរុប/ទម្ងន់មាន់សរុប** | | | | | | **7,464** |
| **ចំណេញលើមាន់សាច់បីសាសន៍ ១គ.ក្រ= តម្លៃមាន់លក់ចេញ(គ.ក្រ)-តម្លៃដើម(គ.ក្រ)** | | | | | | **1,036** |
| **ចំណូលពីការលក់លាមក= លាមកមាន់ ៦០០បាវ X ៣,០០០៛/បាវ** | | | | | | **1,800,000** |
| **ចំណេញសរុបក្នុងវគ្គ(២ខែ)= ចំណេញពីការលក់មាន់សាច់ + ចំណូលពីការលក់លាមក** | | | | | | **17,309,267** |

## ៤-៣-លទ្ធភាពចំណេញក្នុង១វគ្គ ដោយផ្អែកលើនិន្នាការតម្លៃ

ផ្អែកតាមនិន្នាការតម្លៃមាន់សាច់បីសាសន៍ កសិករអាចទទួលបានប្រាក់ចំណេញសមរម្យក្នុងរយៈពេលចិញ្ចឹមមាន់២ខែ/វគ្គ ដោយមានតម្លៃលក់ចន្លោះចាប់ពី ៧,០០០៛/គក្រ ដល់ ១០,០០០៛/គក្រ÷

| តម្លៃលក់ ៛/គក្រ | ទិន្នផល គក្រ | ចំណូល | | ចំណាយសរុប (៛) | ចំណេញ-ខាត | |
|---|---|---|---|---|---|---|
| | | លាមក | សរុប(៛) | | (៛) | ភាគរយ(%) |
| 7,000 | 14,976 | 1,800,000 | 106,632,000 | 111,786,733 | -5,154,733 | -5% |
| 7,500 | 14,976 | 1,800,000 | 114,120,000 | 111,786,733 | 2,333,267 | 2% |
| 8,500 | 14,976 | 1,800,000 | 129,096,000 | 111,786,733 | 17,309,267 | 15% |
| 9,000 | 14,976 | 1,800,000 | 136,584,000 | 111,786,733 | 24,797,267 | 22% |
| 9,500 | 14,976 | 1,800,000 | 144,072,000 | 111,786,733 | 32,285,267 | 29% |
| 10,000 | 14,976 | 1,800,000 | 151,560,000 | 111,786,733 | 39,773,267 | 36% |
| 10,500 | 14,976 | 1,800,000 | 159,048,000 | 111,786,733 | 47,261,267 | 42% |
| 11,000 | 14,976 | 1,800,000 | 166,536,000 | 111,786,733 | 54,749,267 | 49% |

## ៥-ហានិភ័យ វិធានការ និងអនុសាសន៍÷

តាមរយៈនៃការចុះស្វែងយល់អាជីវកម្មនៅកសិដ្ឋានចិញ្ចឹមមាន់សាច់បីសាសន៍នៅឃុំភ្នំតូច ស្រុកសាមគ្គីមុនីជ័យ ខេត្តកំពង់ស្ពឺ ឃើញថាការចិញ្ចឹមមាន់អាចជួបប្រទះនូវហានិភ័យមួយចំនួនជាយថាហេតុប៉ះពាល់ដល់ដំណើរការផលិតកម្ម ដូចនេះកសិករចិញ្ចឹមមាន់គួររៀបចំផែនការជាក់លាក់ដើម្បីកាត់បន្ថយ ឬគ្រប់គ្រងហានិភ័យប្រកបដោយប្រសិទ្ធភាពខ្ពស់។

**ហានិភ័យចម្បងៗក្នុងការចិញ្ចឹមមាន់សាច់បីសាសន៍រួមមានដូចខាងក្រោម÷**

| ល.រ | ប្រភេទហានិភ័យ | ការពិពណ៌នាពីហានិភ័យ | វិធានការ និងអនុសាសន៍ |
|---|---|---|---|
| ១ | ហានិភ័យផលិតកម្ម | ទិន្នផលដែលទទួលបានទាបជាងការរំពឹងទុកបណ្តាលមកពី÷<br>-កូនមាន់ពូជមិនសូវល្អ<br>-អាកាសធាតុឡើងក្តៅខ្លាំងខុសពីធម្មតា<br>-ដឹកជញ្ជូនយូរពេក<br>-កូនមាន់ញីច្រើនពេក<br>-ពុំមានកម្មវិធីវ៉ាក់សាំងត្រឹមត្រូវ | -សិក្សាប្រវត្តិក្រុមហ៊ុនលក់កូនមាន់ឱ្យបានច្បាស់លាស់<br>-ត្រូវរើសកូនមាន់ដែលមានសុខភាពល្អមានទំហំប៉ុនៗគ្នា មានរោមភ្លឺរលោង<br>-បាតជើងមិនមានដំបៅ ដំណើររហ័សរហួន<br>-សម្លេងឮច្បាស់ មិនស្អក<br>-មានកែវភ្នែកភ្លឺថ្លា<br>-តាមដានទម្ងន់មេបា និងប្រវត្តិដើមនៃការបង្កាត់ពូជ |
| | | ចំណីក្រុមហ៊ុនថយចុះគុណភាព ឬជិតផុតកំណត់ ខ្វះខាតប្រភពទឹក និងអគ្គិសនី | -ស្វែងរកក្រុមហ៊ុនដែលធានាលើគុណភាពចំណីថេរ<br>-រៀបចំអាងស្តុកទឹកឱ្យបានគ្រប់គ្រាន់ និងរក្សាអនាម័យទឹក<br>-មានទឹកស្អាតសម្រាប់ផឹកគ្រប់គ្រាន់ជាប្រចាំ<br>-ត្រូវមានប្រភពអគ្គិសនីដទៃទៀតសម្រាប់ប្រើបណ្តោះអាសន្ន |
| ២ | ហានិភ័យទីផ្សារ | លទ្ធភាពនៃការបាត់បង់ទីផ្សារ ឬតម្លៃដែលទទួលបានទាបជាងការរំពឹងទុកតម្លៃទីផ្សារមាន់សាច់ប្រែប្រួលមិនច្បាស់លាស់ពិសេសនៅរដូវសំបូរត្រីធម្មជាតិ | -មានលទ្ធភាពផ្គត់ផ្គង់មាន់សាច់ច្បាស់លាស់<br>-ចុះកុងត្រាទិញលក់ ជាមួយក្រុមហ៊ុនផ្គត់ផ្គង់ពូជ និងចំណី ឬក្រុមហ៊ុនផ្សេងៗទៀត<br>-ចងក្រងបណ្តុំអ្នកចិញ្ចឹមមាន់សាច់ដើម្បីមានបណ្តាញទីផ្សារច្រើន<br>-លក់រាយក្នុងភូមិ និងតាមកម្មវិធីបុណ្យទានផ្សេងៗ |

| | | | |
|---|---|---|---|
| ៣ | **ហានិភ័យហិរញ្ញវត្ថុ** | ការមិនមានសាច់ប្រាក់គ្រប់គ្រាន់ដើម្បីត្រៀមបម្រុងសម្រាប់ទប់ទល់នឹងហេតុការណ៍កើតឡើងដោយចៃដន្យ ដូចជា៖ ខ្វះថវិកានៅក្នុងដំណើរការចិញ្ចឹម ពេលខ្លះត្រូវបង្ខំចិត្តលក់មាន់សាច់ពុំទាន់គ្រប់ទម្ងន់ក្នុងតម្លៃទាប | -ត្រូវមានផែនការអាជីវកម្មច្បាស់លាស់<br>-ត្រូវមានទុនបម្រុងក្រៅពីទុនវិនិយោគ<br>-ត្រូវមានទុនដែលជាឥណទានមានអត្រាការប្រាក់ទាប |
| ៤ | **ហានិភ័យបរិស្ថាន** | ពេលមានសម្លេងរំខាន និងក្លិនស្អុយដល់អ្នកជិតខាង | -ត្រូវចិញ្ចឹមនៅក្នុងចម្ការ ឬឆ្ងាយផ្ទះប្រជាជនរស់នៅ<br>-ត្រូវធ្វើអនាម័យជាប្រចាំ ទុកដាក់លាមកមាន់ឱ្យបានត្រឹមត្រូវនិងរៀបចំប្រព័ន្ធជីវសុវត្ថិភាព |

## ៦-សេចក្តីសន្និដ្ឋាន ៖

មាន់សាច់បីសាសន៍ជាបក្សីធំធាត់លឿន ឆាប់បានផលដោយប្រើរយៈពេលចិញ្ចឹមខ្លី(២ខែ) មានតម្លៃសមស្របទៅនឹងកម្រិតជីវភាពប្រជាពលរដ្ឋទូទៅ អាចយកទៅកែច្នៃជាម្ហូបបានច្រើនមុខ មានអនាម័យ និងសុវត្ថិភាពខ្ពស់ក្នុងការបរិភោគ ព្រមទាំងមានទីផ្សារល្អទាំងបោះដុំ និងលក់រាយ។ តាមការចុះសិក្សាជាក់ស្តែងការចិញ្ចឹមមាន់សាច់បីសាសន៍របស់កសិករនៅខេត្តកំពង់ស្ពឺ លើការចិញ្ចឹមមាន់ចំនួន ១២,០០០ក្បាល ដោយប្រើពេល២ខែ/វគ្គ ទទួលបានទម្ងន់ជាមធ្យម ១,៣គក្រ/ក្បាល ដោយចំណាយថ្លៃដើមផលិត ៧,៥៦៤រៀល/គក្រ អាចទទួលបានប្រាក់ចំណេញប្រមាណ ១,០៣៦រៀល/គក្រ។ ក្នុង១វគ្គកសិករអាចទទួលបានប្រាក់ចំណេញជាង ១៧លានរៀល ប៉ុន្តែប្រាក់ចំណេញអាចលើស ឬតិចជាងនេះអាស្រ័យលើអត្រាបាត់បង់ និងតម្លៃលើទីផ្សារ។ ដើម្បីទទួលបានប្រាក់ចំណេញច្រើន កសិករគួរគិតគូរលើកត្តាចាំបាច់មួយចំនួនដូចជា ការជ្រើសរើសកូនមាន់ពូជ ការថែទាំដោយធ្វើអនាម័យស្នូកទឹក ស្នូកចំណី គុណភាពចំណីសមស្របនឹងតម្លៃ ធ្វើកម្មវិធីវ៉ាក់សាំងបានទៀងទាត់ និងមានទីផ្សារបោះដុំច្បាស់លាស់។

**ប្រភពសិក្សាស្រាវជ្រាវ ÷**


១. កសិករចិញ្ចឹមមាន់សាច់បីសាសន៍ នៅឃុំភ្នំតូច ស្រុកសាមគ្គីមុនីជ័យ ខេត្តកំពង់ស្ពឺ

២. ក្រឹស្នា, ក. (២០២២). Animal Nutrition. In animal Nutrition

៣. ចាន់ថន, ម. (២០២៤) ការអនុវត្តកសិដ្ឋានបសុបក្សីទំនើបប្រកបដោយសុវត្ថិភាព

៤. Pradeep. (2020, july 2020). Poultry =>A Comprehensive Guide to Broiler Management: Farm to Fork. Retrieved from nav farm: https://www.navfarm.com/blog/guide-to-broiler-management/

៥. Gregory Rich. (2022). Cage Hygiene in Birds. Retrieved from Cage Hygiene in Birds: https://vcacanada.com